# សុន្ទរកថា
# ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងការបរទេស
# និងសហប្រតិបត្តិការអន្តរជាតិ
# ថ្លែងក្នុងពិធីអបអរសាទរខួបលើកទី ១០៧
# ទិវាអន្តរជាតិនារី ៨ មីនា
# ថ្ងៃពុធ ទី០៧ ខែមីនា ឆ្នាំ២០១៨

*- លោកជំទាវ ឯកឧត្តម*

*-លោកស្រី អស់លោក*

*-អង្គពិធីទាំងមូលជាទីមេត្រី,*

ខ្ញុំពិតជាមានសេចក្តីរីករាយក្រៃលែង ដោយបានមកចូលរួមក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារីជាមួយថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នារសៀលនេះ។ ឆ្នាំនេះជាខួបលើកទី ១០៧ ហើយកម្ពុជាយើងប្រារព្ធទិវាដ៏មានអត្ថន័យនេះក្រោមប្រធានបទ « ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីអភិវឌ្ឍន៍ជាតិ » ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងនូវការកោតសរសើរដោយស្មោះចំពោះក្រុមការងារ Gender របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានជំរុញ និងរៀបចំកម្មវិធីនេះឡើងដើម្បីអបអរសាទរ និងរំលឹកពីប្រវត្តិនៃការ

តស៊ូ និងជោគជ័យរបស់ស្ត្រីក្នុងការទាមទារដណ្ដើមយកមកនូវសិទ្ធិខាងសេដ្ឋកិច្ច សង្គម និងនយោបាយដែលជាង ១០០ឆ្នាំមុននេះ សិទ្ធិទាំងនោះពុំត្រូវបានជានា និងផ្ដល់ជូនស្ត្រីនោះឡើយ។

ខ្ញុំបានតាមដានស្ដាប់ដោយក្ដីគោរពបំផុតនូវព្រះរាជសាររបស់ សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈនៃយើងទាំងអស់គ្នា ព្រមទាំងស្ដាប់នូវចំណាប់អារម្មណ៍របស់លោកជំទាវ អ៊ិត សោភា ក្នុងនាមជាតំណាងរបស់ស្ត្រីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

*-លោកជំទាវ ឯកឧត្តម លោកស្រី អ្នកនាងកញ្ញា អស់លោក ជាទីមេត្រី!*

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមលើកបញ្ហា៣យ៉ាងដូចតទៅ ៖

ទី១ ខ្ញុំសូមបកស្រាយពីអត្ថន័យនៃប្រធានបទនៃទិវាអន្តរជាតិនារី ដែលក្រសួងកិច្ចការនារី បានជ្រើសរើសយកសម្រាប់ឆ្នាំ២០១៨នេះ គឺ «ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីអភិវឌ្ឍន៍ជាតិ» ។

ប៉ុន្មានថ្ងៃនេះ ថ្នាក់ដឹកនាំក្រសួងកិច្ចការនារីបានចូលរួមក្នុងកម្មវិធីជាច្រើនតាមស្ថាប័នថ្នាក់កណ្ដាល និងក្រោមជាតិដើម្បីអបអរសាទរទិវានេះ ព្រមទាំងថ្លែងសុន្ទរកថាដែលបកស្រាយអត្ថន័យនៃប្រធានបទខាងលើនេះ។ មូលហេតុដ៏សំខាន់

បំផុតដែលនាំឲ្យជ្រើសរើសប្រធានបទនេះគឺ ដើម្បីរំលេចពីតម្លៃមិនអាចកាត់ថ្លៃបាននៃសុខសន្តិភាព ដែលបានមកដោយការដឹកនាំដ៏ត្រឹមត្រូវ ភ្លឺស្វាង និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមពន្យល់បន្ថែមទៀត ដោយយកឃ្លានៃប្រធានបទនេះមកបកស្រាយដូចតទៅ ៖

- ពាក្យដំបូងគេគឺ «ស្ត្រី»។ (ដើម្បីរំលឹកដល់ប្រុសៗថា មិនមែនជាទិវាបុរសទេ!)
- បន្ទាប់មកគឺ «រួមគ្នា» គឺស្ត្រីទាំងអស់រួមគ្នា ធ្វើការជាមួយគ្នា រួមកម្លាំងគ្នា ស្រុះគ្នា មិនមែនម្នាក់ឯង ឬស្ត្រីខ្លះនោះទេ។
- «រក្សាសន្តិភាព» អត្ថន័យពីរយ៉ាងគឺ ទី១ «រក្សា», ពាក្យថា រក្សា គឺសំដៅលើអ្វីដែលយើងមានហើយ តែត្រូវរក្សាឲ្យគង់វង្ស គត់មុត កុំឲ្យបាត់បង់ទៅវិញ។ អត្ថន័យទី២ គឺ« សន្តិភាព » សំដៅរក្សាសន្តិភាពដែលយើងទទួលបាន និងកំពុងមាននៅក្នុងទូទាំងប្រទេស។

តែសំរាប់អ្នកមិនដែលឆ្លងកាត់សង្គ្រាម ទុក្ខវេទនានៃការបំផ្លិចបំផ្លាញ បែកបាក់ បាត់បង់ញាតិមិត្ត ទ្រព្យសម្បត្តិ បាត់បង់អ្នកដែលខ្លួនស្រលាញ់ បាត់បង់ភាពសុខសាន្ត បាត់បង់

ឱកាស ក្ដីសង្ឃឹមនោះ ពាក្យសន្តិភាពមួយម៉ាត់មិនមានន័យជ្រៅជ្រះ សំរាប់ពួកគេទេ។ គេថា «អ្នកមិនដែលអត់ងងុយ មិនបានដេកមួយយប់ទល់ភ្លឺទេ មិនដឹងថាយប់វែងយូរប៉ុណ្ណានោះឡើយ» ។ អ្នកមិនបានឆ្លងកាត់របបប៉ុល ពត មិនស្គាល់ថា តើអ្វីទៅជាការឃ្លានរាល់ថ្ងៃ មួយឆ្នាំ ៣៦៥ថ្ងៃនោះ ?

សន្តិភាពមានតម្លៃណាស់ សំរាប់ជាតិ សំរាប់ប្រទេស សំរាប់ប្រជាពលរដ្ឋគ្រប់រូប ។

ឧទាហរណ៍ នៅថ្ងៃ ១៧ មេសា ១៩៧៥ ប្រជាជនទីក្រុងភ្នំពេញបានចេញពីផ្ទះយ៉ាងពពាក់ពពូន មកអបអរសាទរការចូលមករបស់កងទ័ពឈុតខ្មៅ ទាំងមិនស្គាល់ពួកគេទាំងមិនដឹងពីអ្វី ដែលមេដឹកនាំខ្មែរក្រហមបានគ្រោងទុកសំរាប់ពួកគេ។ ហេតុអ្វី? គឺព្រោះតែគេគិតថា សង្ឃឹមប្រទេសមានសន្តិ-ភាពវិញហើយ ព្រោះគេបានរង់ចាំសន្តិភាពនេះយូរហើយ ព្រោះគេបានយល់ដឹងពីតម្លៃនៃសន្តិភាពនេះ បន្ទាប់ពីបានរងទុក្ខវេទនាដោយសារសង្គ្រាម៥ឆ្នាំក្រោយរដ្ឋប្រហារឆ្នាំ៧០។ អ្វីដែលកើតឡើងបន្ទាប់មក គឺជារឿងមួយទៀត។

- ពាក្យបន្ត គឺ «ដើម្បីអភិវឌ្ឍន៍ជាតិ» ។ ឥឡូវនេះ នៅគ្រប់វេទិកាអន្តរជាតិ និងតំបន់ ពាក្យ២នេះត្រូវបានគេផ្សាភ្ជាប់គ្នាមិនដាច់ គឺសន្តិភាព និងការអភិវឌ្ឍ។

គ្មានសន្តិភាព គឺគ្មានការអភិវឌ្ឍន៍ ។

គ្មានការអភិវឌ្ឍក៏គ្មានសន្តិភាពស្ថិតស្ថេរយូរអង្វែងដែរ ។

តំលៃវត្ថុបំណង គោលដៅ២នេះ ជាទ្រព្យដែលប្រទេសជាតិទាំងអស់នៅលើលោកប្រាថ្នា ប្រឹងប្រែង ឈោងចាប់គ្រប់ៗគ្នា ។ ( MM, PH, TH, RCA, Mali, Sudan, Lebanon... )

ជាតំលៃ២ ដែលពឹងផ្អែកគ្នាទៅវិញទៅមក និងផ្តល់ឲ្យគ្នាទៅវិញទៅមក ។

សង្គ្រាមនាំមកនូវការបំផ្លិចបំផ្លាញ។ សង្គ្រាមស្រូបយកធនធានទាំងអស់របស់ជាតិសំរាប់បំរើអោយការច្បាំងគ្នា។ ទ្រព្យ និងធនធានសំរាប់ការអភិវឌ្ឍន៍មានតិចតួច បើសិនជាមានសេសសល់ ។

ប្រទេសដែលបានសន្តិភាពហើយ តែមិនចេះអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិខ្លួនក្នុងដំណើររឹងមាំនោះទេ ក៏មិនអាចធានាឲ្យសន្តិភាពដែលបានមកដោយលំបាកនោះ ស្ថិតស្ថេរគង់វង្សបានដែរ ។

សន្តិភាពអនុញ្ញាតឲ្យបង្វែគ្រប់ធនធានរបស់ប្រទេសជាតិឆ្ពោះទៅការកសាង ការរីកចំរើន ការកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ លើកស្ទួយការអប់រំ សុខាភិបាល វប្បធម៌ ។ល។ អ្នកទេសចរណ៍ ធ្វើដំណើរទៅកាន់ប្រទេសដែលមានសន្តិ-ភាព ។ សន្តិភាពពង្រឹងទំនុកចិត្តអ្នកវិនិយោគ។ សន្តិភាពផ្តល់សុវត្ថិ-ភាព ភាពសុខសាន្តរបស់គ្រួសារ និងសង្គម ។

ស្ត្រីជាតួអង្គសំខាន់មិនអាចខ្វះបានក្នុងសង្គមជាតិ។ស្ត្រីខ្មែរយើងត្រូវបានសង្គមលើកដំកើង ផ្តល់តួនាទី ឋានៈ តាំងពីបុរំបុរាណកាលមក។( ពាក្យ «មេ» )

ពាក្យថា «រក្សាសន្តិភាព» មិនសំដៅទៅលើការបំពាក់និងប្រើប្រាស់អាវុធ ការពារប្រទេស ការពារសន្តិភាព តែមួយមុខនោះទេ។ ពិតហើយ ក្នុងចំណោមកងទ័ពមួកខៀវកម្ពុជា ជាង ៥.១៧០នាក់ ដែលបានចេញទៅបំពេញបេសកកម្មរក្សាសន្តិភាពរបស់ អ.ស.ប. នៅប្រទេស៨ នៅទ្វីបអាហ្វ្រិក មជ្ឈឹមបូព៌ា និងអឺរ៉ុប ក្នុងរយៈពេល១២ឆ្នាំកន្លងមក គឺមានកងទ័ពជាស្ត្រី ២៣០នាក់ ។ ប៉ុន្តែការរក្សាសន្តិភាព គឺអាចធ្វើឡើងតាមមធ្យោបាយផ្សេងទៀតច្រើនណាស់ តួយ៉ាងការរួមគ្នាការពារឯករាជ្យ អធិបតេយ្យ សន្តិភាព ស្ថិរភាព ប្រឆាំងនិងការជ្រៀតជ្រែកពីខាងក្រៅ ប្រឆាំងនឹងការប៉ុនប៉ងនាំបដិវត្តន៍ពណ៌ ដើម្បីផ្លាស់ប្តូររបបតាមមធ្យោបាយមិនមែនប្រជាធិបតេយ្យនៅកម្ពុជា ឬក៏ការរួមគ្នាជំរុញការអភិវឌ្ឍប្រទេសជាតិ ដើម្បីពង្រឹងខឿនសន្តិភាពឲ្យកាន់តែរឹងមាំថែមទៀតជាដើម ។ (Comments)

មិនមែនជាការចៃដន្យទេ ដែលការអភិវឌ្ឍនៅប្រទេសយើងបានចាប់ផ្តើមដំណើរដ៏រឹងមាំ ស្របពេលដែលកម្ពុជាបានទទួលសន្តិភាពទាំងស្រុងនោះ ។ (Chiffres )

បញ្ហាទី២ដែលខ្ញុំចង់លើក គឺតួនាទី និងការរួមចំណែកកាន់តែធំឡើង សំខាន់ឡើង ចាក់ឬសកាន់តែជ្រៅរបស់ស្ត្រីខ្មែរ

យើងក្នុងរាល់សកម្មភាពរបស់សង្គមជាតិទាំងមូល។នេះក៏ដោយសារការគិតគូរយកចិត្តទុកដាក់ និងការកំណត់បន្ទាត់នយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីក្តាប់រាល់បញ្ហារបស់ស្ត្រី ដោះស្រាយទាន់ពេលវេលា គិតគូរកែប្រែស្ថានភាពរបស់ស្ត្រី និងកុមារឲ្យបានល្អប្រសើរជាលំដាប់ តាមរយៈការបង្កើតយន្តការគ្រប់គ្រងសម្របសម្រួល និងការផ្តល់តួនាទី និងការទទួលខុសត្រូវជូនស្ត្រីនៅគ្រប់កំរិត ។ (គ្រប់ខេត្ត ស្រុក ឃុំ រហូតដល់ ភូមិ, តាមក្រសួងស្ថាប័ន ដូចជាក្រុមការងារបញ្ជ្រាបយេនឌ័រ ថ្នាក់ដឹកនាំរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ។ ៤១% នៃមន្ត្រីរាជការជាស្ត្រី (ឆ្នាំ២០១៧ មាន ៣២% ។ល។) ស្ត្រីដែលដឹកនាំធុរកិច្ចប្រកបដោយជោគជ័យ មានកាន់តែច្រើន ឯវិសាលភាពនៃមុខរបររបស់គាត់ ក៏កាន់តែទូលាយ ។ ខ្លះគ្រប់គ្រងមុខរបរពហុវិស័យដែលបុរសជាអ្នករកស៊ីដូចគ្នាជាច្រើន មានសមត្ថភាពមិនស្មើផង ។ (ថៅកែស្រី ឧកញ៉ា ឈុន លាង ចែទូ ជីពម៉ុង ស៊ុយសុផាន យាយស្រ៊ាន់ ។ល។ រួមទាំង Entrepreneurs វ័យក្មេងជាច្រើនទៀត ...)

សិស្សស្រីដែលជាប់និទ្ទេស A មានចំនួនត្រដំត្រសងនឹងសិស្សប្រុសដែរ ដែលប្រការនេះផ្តល់សេចក្តីសង្ឃឹមដ៏រឹងមាំទៅអនាគត ។

កម្មការនីតាមរោងចក្រភាគច្រើនលើសលុបជាស្ត្រីបញ្ជាក់ពីឋាមភាពរបស់កំលាំងស្ត្រីក្នុងការបង្កើនផលិតភាពជាតិ

និងរួមចំណែកដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចក្នុងវិស័យដ៏សំខាន់នេះ ។ (+anecdote)

បញ្ហាទី៣ គឺទាក់ទងផ្ទាល់នឹងស្ត្រីក្នុងក្រសួង ក.ប.ស.អ. យើង។ លោកជំទាវ អ៊ាត សោភា បានលើកមុននេះអំពីការងារដែលស្ត្រីយើងនៅក្រសួងសម្រេចបាន ការប្រឈមដែលនៅជួបប្រទះ និងសំណូមពរទាំងឡាយរបស់ស្ត្រីនៅទីនេះ ដើម្បីធ្វើឲ្យលក្ខខណ្ឌ ប្រសិទ្ធភាព និងលទ្ធផលការងាររបស់យើងកាន់តែប្រសើរថែមទៀត ។ (បកស្រាយ)

សព្វថ្ងៃនេះ ថ្នាក់ដឹកនាំក្រសួងយើងមានតែអនុរដ្ឋលេខាធិការមួយរូបជាស្ត្រី ។ រដ្ឋលេខាធិការម្នាក់ជាស្ត្រី បានផ្លាស់ទៅធ្វើឯកអគ្គរាជទូតនៅ UK ធ្វើឲ្យចំនួនឯកអគ្គរាជទូតជាស្ត្រីរបស់យើងមាន៦រូបគឺ China, UK, Japan, Germany, The Philippines និង Malaysia ។ ប្រធាននាយកដ្ឋានបុគ្គលិកជាស្ត្រី។ តើឲ្យនរណាគិតគូរពីស្ត្រីក្នុងក្រសួង លើសពីស្ត្រីគ្នាឯង ?

ស្ត្រីអ្នកការទូតមានប្រៀបជាងមួយលើបុរស៖ បុរសៗមិនសូវហ៊ានឈ្លោះជាមួយស្ត្រីនោះទេ។ ក្នុងចំណោមអ្នកការទូតវ័យក្មេង យើងនឹងខិតខំយកចិត្តទុកដាក់បណ្តុះបណ្តាលស្ត្រីវ័យក្មេងឲ្យកាន់តែច្រើន ។

តែយើងដឹងទាំងអស់គ្នាហើយថា លក្ខខណ្ឌនិងលក្ខណៈសម្បត្តិនៃការជ្រើសរើសអ្នកការទូតរបស់យើង គឺមាននិយាមនិងលំនាំតែមួយដូចគ្នាទាំងសម្រាប់បុរស និងស្ត្រី ពោលគឺ

សមត្ថភាព ភាពសកម្ម និងស្មារតីស្នេហាជាតិ ។ យើងនឹងខិតខំពង្រឹង និងលើកកំពស់វិជ្ជាជីវៈរបស់មន្ត្រីការទូតរបស់យើង តាមរយៈការបង្កើតឡើងនូវវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ និងតាមរយៈកម្មវិធីបំប៉នផ្សេងៗទៀត។

ដូចខ្ញុំបានលើកឡើងក្នុងសុន្ទរកថាបើកសន្និបាតប្រចាំឆ្នាំរបស់ក្រសួងកាលពីសប្តាហ៍មុននេះថា «ការប្រែប្រួលដ៏ជ្រាលជ្រៅ ស្មុគ្រស្មាញ ហើយដែលពិបាកប៉ាន់ស្មានបាន នៃស្ថានការណ៍តំបន់ និងពិភពលោក កាន់តែតម្រូវឲ្យកម្ពុជាយើង មានអង្គអ្នកការទូត មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញដ៏មានសមត្ថភាពដើម្បីឆ្លើយតបទៅនឹងការប្រឈមថ្មីៗទាំងនោះ» ។

ការការពារឯករាជ្យអធិបតេយ្យ សន្តិភាព និងស្ថេរភាពរបស់ប្រទេសយើង បានក្លាយជាការងារចំបងទី១ របស់ក្រសួង ក.ប.ស.អ. ។ នេះក៏ស្របទៅនឹងប្រធានបទឆ្នាំ២០១៨នេះរបស់ចលនានារីយើងនៅទូទាំងប្រទេសដែរ។ កំលាំងនារីក្នុងប្រទេស នឹងរួមជាមួយកំលាំងនារីយើងនៅក្រៅប្រទេសដើម្បីថែរក្សាសន្តិភាព ដែលជាភោគទ្រព្យមិនអាចកាត់ថ្លៃបាន និងអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យកាន់តែរីកចំរើនរុងរឿងថែមទៀត ។

ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរ លោកជំទាវ លោកស្រី និងអ្នកនាងកញ្ញា ទាំងអស់ សូមបានសំរាកកាយសប្បាយចិត្ត ត្បិតថ្ងៃស្អែកជាថ្ងៃឈប់សម្រាកទិវាអន្តរជាតិនារី៨មិនា និងសូមអង្គ

ពិធីទាំងមូលបានប្រកបតែនឹងពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត ឡើយ។ **សូមអរគុណ !**